ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ
THE STUDENT MOVEMENT FOR DEMOCRACY

លេខ៖ ០០១៥/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីតុន ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

# សេចក្ដីថ្លែងការណ៍

## ប្រឆាំងចោលការបម្លែងខ្នាតផែនទី ១/២៥.០០០
## ក្នុងការបោះបង្គោលព្រំដែនកម្ពុជា-វៀតណាម ក្នុងស្ថានភាពកម្ពុជាបច្ចុប្បន្ន

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមប្រានចោលដាច់ខាត នូវការប្រើប្រាស់ខ្នាតផែនទី ១/២៥.០០០ ក្នុងស្ថានភាពបច្ចុប្បន្ន ដែលធ្វើឡើងដោយតំណាងរដ្ឋាភិបាលវៀតណាម លោក **Le Hoai Trung** អនុរដ្ឋមន្ត្រីក្រសួងការបរទេស និងតំណាងរដ្ឋាភិបាលកម្ពុជា លោក **វ៉ា គឹមហុង** ប្រធានគណៈកម្មាធិការចម្រុះព្រំដែនកម្ពុជា កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០។

ទីភ្នាក់ងារសារព័ត៌មានវៀតណាម(VNA) ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ រាយការណ៍ថា៖ *«ភាគីទាំងពីរបានផ្ទៀងផ្ទាត់ ពិនិត្យ និងឯកភាព លើផែនទីព្រំដែនចំនួន ៥០០ផ្ទាំង ... ដោយមានការចុះហត្ថលេខាពីតំណាងនៃប្រទេសទាំងពីរ»*។ សេចក្ដីរាយការណ៍នេះ បន្ថែមថា *«ផែនទីទាំងនោះ គឺជាផ្នែកនៃការកំណត់ព្រំដែនគោករវាង វៀតណាម-កម្ពុជា ដែលបានចុះហត្ថលេខា ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៩ តាមមូលដ្ឋាននៃសន្ធិសញ្ញាបំពេញបន្ថែម លើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥»*។

យើងខ្ញុំសូមបង្ហាញអំពីកំហុសនៃការបម្លែងខ្នាតផែនទី ទៅជា ១/២៥.០០០ នេះ ដូចខាងក្រោម ៖

***ទី១-*** ផែនទីខ្នាត ១/២៥.០០០ ផ្ទុយពីខ្លឹមសាររដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា២ នៃជំពូកទី១ អំពីអធិបតេយ្យ ចែងថា *«បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ក្នុងផែនទី ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះ ននឆ្នាំ១៩៦៣-១៩៦៩»*។

***ទី២-*** រឿងបម្លែងមាត្រដ្ឋានផែនទី គឺជាកិច្ចការបច្ចេកទេស ដែលមានលក្ខណៈសុក្រឹត និងអាចទទួលយកបាន លុះត្រាតែមានការចូលរួមពីភាគីពាក់ព័ន្ធប្រវត្តិផែនទី នៃក្រុមភូមិសាស្ត្រឥណ្ឌូចិន-បារាំង ដូចជាប្រទេសបារាំង មន្ត្រីជំនាញបច្ចេកទេសនៃអង្គការសហប្រជាជាតិ និងភាគីទំនាស់ទាំងពីរ គឺកម្ពុជា និងវៀតណាម។ ករណីផែនទីនេះ ពុំអាចគប់គិតសម្រេចធ្វើស្វាត់ៗ ត្រឹមទ្វេភាគី តែរវាងកម្ពុជា និងវៀតណាម ហើយបោះពុម្ពនៅប្រទេសដាណឺម៉ាក ឬប្រទេសណាមួយ ស្រេចតែនឹងចិត្តនោះទេ ពីព្រោះ ៖

- កិច្ចព្រមព្រៀងក្រុងប៉ារីស៍ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានដាក់ជា*«**មោឃភាព**» អស់ហើយនូវសន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និងឆ្នាំ១៩៨៥*។
- សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងឆ្នាំ២០១៩ ដែលជាមូលដ្ឋានសហប្រតិបត្តិការ រវាងរដ្ឋាភិបាល

កម្ពុជាបច្ចុប្បន្ន និងវៀតណាម ក៏ជាការបំពានរដ្ឋធម្មនុញ្ញកម្ពុជា និងកិច្ចព្រមព្រៀងក្រុងប៉ារីស៍ ដែលវៀតណាមជាប្រទេសហត្ថលេខីដែរ។

***ទី៣-*** រដ្ឋាភិបាលកម្ពុជានៃ **លោក ហ៊ុន សែន** ពុំមានលក្ខខណ្ឌប្រតិបត្តិតម្លា ក្នុងការបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាង ជាពិសេសការធ្វើជាមួយប្រទេសវៀតណាម ចំនួន ៣១៥ បង្គោល (៨៤ ភាគរយ) ដែលមិនអាចជម្រះសេចក្តីមន្ទិលសង្ស័យរបស់ប្រជាពលរដ្ឋខ្មែរជាម្ចាស់ទឹកដីបានឡើយ។ លក្ខខណ្ឌប្រតិបត្តិកន្លងមក និងបច្ចុប្បន្ន មានចរិតបិទបាំងការពិត ពីប្រជាពលរដ្ឋខ្មែរ ពីព្រោះ ៖

- ពុំបានបើកចំហឲ្យមានការចូលរួមពីចម្រុះភាគីជាតិ ដូចជាគណបក្សប្រឆាំង សង្គមស៊ីវិល អ្នកជំនាញទាំងក្នុង និងក្រៅប្រទេស និងតំណាងព្រះមហាក្សត្រ ដែលជាទីទុកចិត្តរបស់ប្រជាពលរដ្ឋខ្មែរ។
- ពុំបានបើកចំហឲ្យមានការចូលរួមពីចម្រុះភាគីអន្តរជាតិ ដូចជាអ្នកជំនាញផែនទី នៃអង្គការសហប្រជាតិ ឬតំណាងសហប្រធាននៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ជាពិសេសអ្នកបច្ចេកទេសផែនទី នៃប្រទេសបារាំង ដែលជាម្ចាស់គំនូសផែនទីដើមនៃប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង។
- កាន់តែមិនអាចទទួលយកបានទៀតនោះ ត្រង់ថា រដ្ឋាភិបាលលោក **ហ៊ុន សែន** តែងតែធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋខ្មែរទាំងឡាយណា ដែលចង់ដឹងការពិតអំពីរឿងផែនដីព្រំដែន ជាឧទាហរណ៍ជាក់ស្តែង ការចាប់ឃុំខ្លួន **លោក រ៉ុង ឈុន** តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាថ្មីៗនេះ ស្របពេលអាជ្ញាធរ នៃប្រទេសវៀតណាមហ៊ានបើកចំហឲ្យពលរដ្ឋវៀតណាម ដឹងឮ និងចុះទៅមើលដល់បង្គោលព្រំដែន។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** មើលឃើញថា ការបម្លែងខ្នាតផែនទី ទៅជា ១/២៥.000 នេះ ទាំងខុសប្រក្រតី និងខុសកាលៈទេសៈជាតិ គឺជាការធ្វើសម្បទានថ្មីបន្ថែមទៀត ឲ្យវៀតណាម ស្ងាត់ៗ និងមិនស្មោះត្រង់ ជាមួយប្រជាជាតិខ្មែរ។ យើងខ្ញុំសូមប្រឆាំងដាច់ខាត ចំពោះការគប់គិតបម្លែងខ្នាតផែនទីនេះ ស្របពេលរដ្ឋាភិបាលកម្ពុជា នៅក្រោមឥទ្ធិពលមេដឹកនាំបក្សកុម្មុសនិស្តវៀតណាម ទាំងនយោបាយ និងការទូត ហើយកម្ពុជា ពុំទាន់មានតុល្យភាពយោធាជាមួយវៀតណាមនៅឡើយ។

សម្រាប់ស្ថានភាពកម្ពុជាបច្ចុប្បន្ន ដែលចាញ់ប្រៀបប្រទេសវៀតណាមយ៉ាងធំធេងលើគ្រប់វិស័យ **ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមទាមទារឲ្យមានការចូលរួមពីចម្រុះភាគីជាតិ និងអន្តរជាតិ ក្នុងការដោះស្រាយបញ្ហាព្រំដែនកម្ពុជា ជាមួយប្រទេសវៀតណាម ទាំងករណីផែនទី និងការវាស់កំណត់លើផែនដីជាក់ស្តែង។

**ប្រធានប្រតិបត្តិ**



**ទូច វិបុល**